លេខ ៤៨ ចេញផ្សាយថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២៥

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## មាតិកា


- ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងប្រជុំពិភាក្សាការងារអំពីវិស័យបរធនបាលកិច្ច នៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន.................ទំព័រទី១
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........................................ទំព័រទី២
- កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦"..............................ទំព័រទី២
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងជូនដំណឹងពីដំណើរការកិច្ចលទ្ធកម្មសម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ.........................ទំព័រទី២
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. និងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន VBANX........................................................ទំព័រទី៣
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ........................................................ទំព័រទី៣
- វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"...................................................ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"..........................ទំព័រទី៤
- កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយប្រតិភូវិនិយោគិននៃសហព័ន្ធទំនាក់ទំនងអាស៊ាននិងតៃវ៉ាន់ និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនក្នុងវិស័យតំបន់សេដ្ឋកិច្ចពិសេស........................................ទំព័រទី៤
- កិច្ចពិភាក្សារវាងធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ីជាមួយ ន.ប.ធ.......................................................ទំព័រទី៥
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃ អ.ស.ហ..........................ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាអំពីការផ្តួចផ្តើមកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា (STEPI).....................................................ទំព័រទី៥
- សិក្ខាសាលា ស្តីពី "កិច្ចពិភាក្សានិងប្រមូលធាតុចូលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមក្នុងការបង្កើតសមាគមបរធនបាលកម្ពុជា" .........,,,.....ទំព័រទី៦
- សិក្ខាសាលាស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"...ទំព័រទី៦
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២៥.................................................ទំព័រទី៧


## ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងប្រជុំពិភាក្សាការងារអំពីវិស័យបរធនបាលកិច្ច នៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន

ចាប់ពីថ្ងៃពុធ ដល់ថ្ងៃសុក្រ ២ ដល់ ៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៨-៣០ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងប្រជុំពិភាក្សាការងារអំពីវិស័យបរធនបាលកិច្ច នៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន។ នៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ គណៈប្រតិភូនៃ **ន.ប.ធ.** បានជួបប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងបទពិសោធន៍អនុវត្តន៍ ក្របខ័ណ្ឌបទប្បញ្ញត្តិបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសម្រាប់ការវិនិយោគ កិច្ចដំណើរការនៃសមាគមក្រុមហ៊ុនបរធនបាល និងសមាហរណកម្មបច្ចេកវិទ្យា ការអភិវឌ្ឍទីផ្សារ ការគ្រប់គ្រងហានិភ័យ លទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការ និងការអនុវត្តប្រកបដោយនិរន្តរភាព ក៏ដូចជាការចែករំលែកអំពីសក្តានុពល និងកាលានុវត្តភាពវិនិយោគក្នុងទីផ្សារបរធនបាលកិច្ចកម្ពុជាផងដែរ ជាមួយប្រធាន និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់សមាគមក្រុមហ៊ុនបរធនបាលនៃប្រទេសជប៉ុន សមាគម Fintech នៃប្រទេសជប៉ុន ធនាគារនិងក្រុមហ៊ុនបរធនបាល Mitsubishi UFJ Trust and Banking Corporation ក្រុមហ៊ុន Japan Funds, Inc. និងក្រុមហ៊ុន Hongo Tsuji Tax & Consulting។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងប្រជុំពិភាក្សាការងារអំពីវិស័យបរធនបាលកិច្ច នៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នាព្រឹកថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោកស្រី ឈាន-សុខារី** និងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងផែនការមេ សម្រាប់ការអភិវឌ្ឍវិស័យមូលបត្រ ឆ្នាំ២០២៥-២០៣៥ របស់ និយ័តករមូលបត្រកម្ពុជា និងសេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មអចលនវត្ថុ របស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦"

នាព្រឹកថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥, **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងសហការី បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦"។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងជូនដំណឹងពីដំណើរការកិច្ចលទ្ធកម្មសម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ"

កាលពីថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែមិថុនា គ.ស.២០២៥ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP-PIU1 អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងជូនដំណឹងពីដំណើរការកិច្ចលទ្ធកម្មសម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និង

ទំព័រទី២

ដៃគូអភិវឌ្ឍពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅសណ្ឋាគារសាន់ & មូន រីវើសាយ។

សិក្ខាសាលានេះ មានការចូលរួមពីឯកឧត្តម លោកជំទាវ លោកនាយកគម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។




**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី “ការដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងជូនដំណឹងពីដំណើរការកិច្ចលទ្ធកម្មសម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ។

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន VBANX

នាព្រឹកថ្ងៃព្រហស្បតិ៍ ២ រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ**២០២៥ ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រជុំជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន VBANX ពាក់ព័ន្ធនឹងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យបរធនបាលកិច្ច និងការទទួលស្គាល់ជាក្រុមហ៊ុនផ្តល់សេវាព័ត៌មានវិទ្យាក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាទិសដៅការងារពាក់ព័ន្ធ។



**រូបភាព៖**កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន VBANX។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នាព្រឹកថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** និងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មអចលនវត្ថុ របស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



**រូបភាព៖** កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## វគ្គបណ្តុះបណ្តាលស្តីពី “ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

ចាប់ពីថ្ងៃពុធ ១រោច ដល់ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១-១៣ ខែមិថុនា ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក

នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធាន PIU1-គ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1), **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1** បានដឹកនាំក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" នៅខេត្តក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពដល់មន្ត្រីបង្គោលនៃគ្រឹះស្ថានហិរញ្ញវត្ថុដៃគូទាំង ២ ដែលបាននិងកំពុងទទួលបន្ទុកអនុវត្តគម្រោង ACSEP តាមបណ្តាខេត្តគោលដៅ អំពីការរៀបចំ និងការបំពេញព័ត៌មានក្នុងទម្រង់ ESMS ដែលជាលក្ខខណ្ឌតម្រូវក្នុងការស្នើសុំឥណទាននៃគម្រោង ACSEP។

វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃខេត្តទាំង ៣ និងក្រុមការងារមកពីតាមបណ្តាខេត្តគោលដៅនៃស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។




រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាសៀលថ្ងៃសៅរ៍ ៤រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តបាត់ដំបង បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម លេខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក សំ សុជា នាយកសាខានៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា** នៅសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តបាត់ដំបង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តបាត់ដំបង។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយប្រតិភូវិនិយោគិននៃសហព័ន្ធទំនាក់ទំនងអាស៊ាននិងតៃវ៉ាន់ និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនក្នុងវិស័យតំបន់សេដ្ឋកិច្ចពិសេស

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩ រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រតិភូវិនិយោគិននៃសហព័ន្ធទំនាក់ទំនងអាស៊ាននិងតៃវ៉ាន់ និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនក្នុងវិស័យតំបន់សេដ្ឋកិច្ចពិសេស វិស័យហិរញ្ញវត្ថុ វិស័យបច្ចេកវិទ្យា វិស័យសំណង់ វិស័យអប់រំ វិស័យភោជនីយដ្ឋាន និងវិស័យសុខាភិបាល ដែលមានចំណាប់អារម្មណ៍វិនិយោគនៅកម្ពុជា ក៏ដូចជា ស្វែងយល់ពីកាលានុវត្តភាពនៃការវិនិយោគរយៈពេលវែងតាមរយៈយន្តការបរធនបាលកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយប្រតិភូវិនិយោគិននៃសហព័ន្ធទំនាក់ទំនងអាស៊ាននិងតៃវ៉ាន់ និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនក្នុងវិស័យតំបន់សេដ្ឋកិច្ចពិសេស។

## កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយ ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី

នាព្រឹកថ្ងៃសុក្រ ១០ រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលជួប **លោក** Nicolas HOLLANDER នាយកប្រតិបត្តិនៃធនាគារ ប្រេដ ប៊ែង (**ខេមបូឌា**) ភីអិលស៊ី និងសហការី ដើម្បីពិភាក្សាការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ព្រមទាំងក្របខណ្ឌប្រតិបត្តិការ និងក្របខណ្ឌច្បាប់នៃបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬរក្សាទុកក្នុងវិស័យបរធនបាលកិច្ច (Retention or Escrow Services) នៅកម្ពុជា។



រូបភាព៖ កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយ ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃ អ.ស.ហ.

នារសៀលថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** និងសហការីបានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មអចលនវត្ថុ របស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃ អ.ស.ហ.។

## កិច្ចប្រជុំពិភាក្សាអំពីការផ្តួចផ្តើមកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (STEPI)

នារសៀលថ្ងៃចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីចូលរួមកិច្ចប្រជុំពិភាក្សាអំពីការផ្តួចផ្តើមកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេក-វិទ្យា (STEPI) ដើម្បីបណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងវិស័យបរធនបាលកិច្ច ជាមួយ**នឹងលោកស្រី** Myonghwa Lee **នាយកនៃ** STEPI **និងលោក** Dong-Un PARK **ប្រធាននាយកដ្ឋានស្រាវជ្រាវសម្រាប់យុទ្ធសាស្ត្រសាកល** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំពិភាក្សាអំពីការផ្តួចផ្តើមកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (STEPI)។

## សិក្ខាសាលា ស្តីពី "កិច្ចពិភាក្សានិងប្រមូលធាតុចូលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមក្នុងការបង្កើតសមាគមបរធនបាលកម្ពុជា"

នាព្រឹកថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា គ.ស.២០២៥ **ន.ប.ធ.** បានរៀបចំកម្មវិធីសិក្ខាសាលា ស្តីពី "កិច្ចពិភាក្សានិងប្រមូលធាតុចូលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមក្នុងការបង្កើតសមាគមបរធនបាលកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** និងមានការចូលរួមពីក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គល និងប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ដើម្បីចូលរួមផ្តល់ធាតុចូលលើការងារបង្កើតសមាគមបរធនបាលកម្ពុជា នៅទីស្តីការរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

កម្មវិធីនេះបានផ្តោតជាសំខាន់លើការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅរបស់សមាគម និងអត្ថប្រយោជន៍នៃការបង្កើតឱ្យមានសមាគមបរធនបាលកម្ពុជា ដែលក្នុងនោះមានដូចជា៖ ការពង្រឹងកិច្ចសហការរវាងគ្នាទៅវិញទៅមក, ការលើកកម្ពស់វិជ្ជាជីវៈ, ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។ នៅក្នុងកម្មវិធីនេះ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធទាំងអស់ បានបង្ហាញក្តីសោមនស្សរីករាយ និងឯកភាពជាឯកច្ឆន្ទៈក្នុងការគាំទ្រគំនិតផ្តួចផ្តើមនៃការបង្កើតសមាគមបរធនបាលកម្ពុជា ក៏ដូចជារីករាយក្នុងការសម្របសម្រួលផ្តល់កិច្ចសហការក្នុងដំណើរការនៃការបង្កើតសមាគមនាពេលឆាប់ៗខាងមុខ ផងដែរ។



រូបភាព៖ សិក្ខាសាលា ស្តីពី "កិច្ចពិភាក្សានិងប្រមូលធាតុចូលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមក្នុងការបង្កើតសមាគមបរធនបាលកម្ពុជា"

## កម្មវិធីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី២ ក្រោមមូលបទ "ការត្រៀមលក្ខណៈរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច"

នាថ្ងៃព្រហស្បតិ៍ ១កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី២ ក្រោមមូលបទ "ការត្រៀមលក្ខណៈរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។



រូបភាព៖ កម្មវិធីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី២ ក្រោមមូលបទ "ការត្រៀមលក្ខណៈរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច"។

## សិក្ខាសាលាស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

នាព្រឹកថ្ងៃសុក្រ ២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" ដល់មន្ត្រីបង្គោលនៃធនាគារធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារស្ថាបនា ភីអិលស៊ី មកពីទូទាំងខេត្តកណ្តាល ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាលនេះ ជាលទ្ធផលនៃការពង្រីកវិសាលភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ ក្នុងកម្រិតទូទាំងប្រទេស

បន្ថែមពីលើខេត្តគោលដៅទាំង ៦ ដែលមានស្រាប់ និងត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹង ក៏ដូចជាពង្រឹងសមត្ថភាពដល់មន្ត្រីនៃធនាគារដៃគូទាំងពីរ មកពីទូទាំងខេត្តកណ្តាល ជាខេត្តគោលដៅថ្មី លើការរៀបចំបំពេញព័ត៌មាន ក្នុងទម្រង់ផលប៉ះពាល់ដល់បរិស្ថាន និងសុវត្ថិភាពសង្គម ដែលជាលក្ខខណ្ឌតម្រូវក្នុងការស្នើសុំឥណទាន និងនីតិវិធីប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្នុងក្របខណ្ឌគម្រោង ACSEP សមាសភាគទី១។

វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាល, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (GDICDM) , តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនាភីអិលស៊ី។



រូបភាព៖ សិក្ខាសាលាស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២៥

នាព្រឹកថ្ងៃសុក្រ ២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋាន,លោកប្រធានស្តីទីនាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមិថុនា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២៥។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888